## Community Justice Centres (មណ្ឌលយុត្តិធម៌សហគមន៍)

Mediation and Conflict Management Services (សេវាគ្រប់គ្រងទំនាស់និងសំរុះសំរួល)

*តើលោកអ្នកចង់មានយោបល់នៅក្នុងដំណោះស្រាយនៃទំនាស់ដែលប៉ះពាល់រូបលោកអ្នកឬទេ?*

**តើមណ្ឌលយុត្តិធម៌សហគមន៍ធ្វើអ្វីខ្លះ?**

មណ្ឌលយុត្តិធម៌សហគមន៍ (CJCs) ផ្តល់សេវាគ្រប់គ្រងទំនាស់និងសំរុះសំរួល ដើម្បីជួយប្រជាជនដោះស្រាយទំនាស់ផ្ទាល់ខ្លួនរបស់គេ។ សេវារបស់យើងគឺផ្តល់ជូន**ដោយឥតគិតថ្លៃ** រក្សាការសម្ងាត់ ដោយស្ម័គ្រចិត្ត ទាន់ពេលត្រឹមត្រូវ ហើយស្រួលពឹងពាក់ទៀតផង។

**តើការសំរុះសំរួលជាអ្វីទៅ?**

ការសំរុះសំរួល គឺការនាំមនុស្សឲ្យជួបជុំគ្នាដើម្បីពិភាក្សាបញ្ហាឬក៏ទំនាស់។

ការជួបសំរុះសំរួលនៅ CJCs ប្រព្រឹត្តទៅដោយមានអ្នកសំរុះសំរួលពីរនាក់ដែលមានការហ្វឹកហាត់ហើយមិនលំអៀង ដែលជួយប្រជាជនឲ្យយល់នូវទស្សនៈរៀងៗខ្លួនទៅវិញទៅមក ហើយធ្វើការជាមួយគ្នាដើម្បីសំរេចឲ្យបាននូវការព្រមព្រៀងមួយ ដែលជនម្នាក់ៗ យល់ព្រមទទួលយក។

អ្នកសំរុះសំរួលរៀបគ្រប់គ្រងនូវរបៀបដែលការជួបប្រជុំនេះដំណើរការ។ មនុស្សពាក់ព័ន្ធនៅក្នុងទំនាស់ធ្វើការសំរេចនូវអ្វីដែលត្រូវពិភាក្សា ហើយនិងអ្វីដែលគេយល់ព្រម។

**ហេតុអ្វីបានជាគួរតែមានការសំរុះសំរួល?**

ការសំរុះសំរួលផ្តល់នូវបរិយាកាសក្រៅផ្លូវការហើយមានសុវត្ថិភាព សំរាប់ឲ្យបណ្តាជនទាំងឡាយនិយាយជាមួយគ្នាទៅវិញទៅមក ដើម្បីដោះស្រាយបញ្ហា។ ការធ្វើយ៉ាងដូច្នេះគឺគ្មានបង់ខាត អ្វីឡើយ។

ការសំរុះសំរួលជាង៨០% នាំសំរេចឲ្យបាននូវការស្រុះស្រួលព្រមព្រៀងគ្នា។ នេះគឺដោយសារបណ្តាជនធ្វើសេចក្តីសំរេចចិត្តដោយខ្លួនឯង ដែលជាហេតុធ្វើឲ្យគេ តាំងចិត្តចង់បានលទ្ធផល។

បើសិនជាមិនមានការសំរេចបាននូវការស្រុះស្រួលត្រូវរ៉ូវគ្នាទេនោះ ក៏គេបានមានឱកាស បំភ្លឺនូវបញ្ហាហើយនិងបានយល់អំពីទស្សនៈរវាងគ្នានិងគ្នាដែរ។

**តើមានអ្វីកើតឡើងនៅក្នុងការសំរុះសំរួល?**

តួនាទីរបស់អ្នកសំរបសំរួល គឺត្រូវគ្រប់គ្រងនិងសំរបសំរួលការពិភាក្សា ដើម្បីឲ្យជនទាំងឡាយអាចសំរេចបាននូវដំណោះស្រាយដែលជាការយល់ឃើញទួទៅ សំរាប់ទំនាស់របស់ខ្លួន។

ដំណើរការនេះជាទួទៅ ប្រព្រឹត្តទៅតាមវិធានការដូចខាងក្រោមនេះ:

⇒ អ្នកសំរុះសំរួលនិងជនដែលមានការជាប់ពាក់ព័ន្ធក្នុងរឿងនេះ ណែនាំឲ្យគេស្គាល់ខ្លួន ហើយ អ្នកសំរបសំរួលពន្យល់អំពីដំណើរការនិង "វិន័យអនុវត្ត" សំរាប់ការសំរុះសំរួលនេះ។

⇒ ជននីមួយៗ លើកនិយាយជាគោលៗអំពីការបារម្ភរបស់ខ្លួន ម្តងម្នាក់ៗ។

⇒ ត្រូវមានការស្តាប់ជននីមួយៗនិយាយដោយគ្មានការបង្អាក់រំខានឡើយ។

⇒ អ្នកសំរបសំរួលជំរុញលើកទឹកចិត្តនិងសំរួលឲ្យមានការពិភាក្សារវាងជនទាំងឡាយ ស្តីអំពីបញ្ហាដែល គេបានលើកឡើង។

⇒ អ្នកសំរបសំរួលជួបជននីមួយៗរៀងៗខ្លួន ដោយទុកពេលឲ្យអ្នកឯទៀតគិតអំពីជំរើសទាំងឡាយរបស់ខ្លួន។

⇒ ក្រោយមកអ្នកសំរបសំរួលនឹងត្រូវនាំជនទាំងនោះឲ្យមកជួបជុំគ្នាវិញ ហើយជំរុញលើកទឹកចិត្តឲ្យគេចរចា អំពីការរៀបចំដោះស្រាយនៅគ្រាអនាគត។

⇒ បើជាមានការយល់ព្រមស្រុះស្រួលទាំងអស់គ្នាហើយ អ្នកសំរបសំរួលត្រូវសរសេរការយល់ព្រមនោះ ហើយផ្តល់ឯកសារនៃការយល់ព្រមនោះ ម្នាក់មួយច្បាប់ៗ ទៅឲ្យជនទាំងនោះ ទុកជាកំណត់ត្រានៃអ្វី ដែលគេបានសំរេចឡើង។

**តើនរណាទៅជាអ្នកសំរបសំរួល?**

អ្នកសំរបសំរួលរបស់ CJC ត្រូវឆ្លងកាត់ដំណើរការជ្រើសរើសយ៉ាងហ្មត់ចត់ ហើយត្រូវបំពេញវគ្គសិក្សា ហ្វឹកហ្វឺនធំទូលាយមួយផង។

អ្នកសំរបសំរួលទាំងនោះបានទទួលបៀវត្សរ៍និងសញ្ញាបត្រទទួលស្គាល់ពីអគ្គមេធាវីនៃរដ្ឋNSW (ញូវសោវ៍វែលស៍) សំរាប់ CJCs ទៅតាមពេលវេលាដែលគេត្រូវការ។

អ្នកសំរបសំរួលទាំងនោះរក្សាជំនាញការរបស់ខ្លួនតាមរយៈការវាយតម្លៃ ការត្រួតពិនិត្យ និងការហ្វឹកហ្វឺនបណ្តុះបណ្តាល ជាប់រហូត។

**តើទំនាស់អ្វីខ្លះដែលសមរម្យសំរាប់ការសំរុះសំរួល?**

ទំនាស់ផ្សេងៗមួយចំនួនធំ ដែលសមរម្យនឹងសំរុះសំរួលបាន រួមមាន:

⇒ អ្នកជិតខាង-របងផ្ទះ, ដើមឈើ, សម្លេងថ្លង់, សត្វចិញ្ចឹម, ច្រកចូល, ភ្លេងតន្ត្រី

⇒ គ្រួសារ-គូស្រករដែលចែកផ្លូវគ្នាដើរ, សាច់ញាតិ, មាតាបិតានិងកូន, អ្នកថែទាំរក្សា

⇒ អាជីវកម្ម- ជាមួយនឹងភ្ញៀវ, អ្នកម៉ៅការ, គុណភាពនៃ/ការបង់ប្រាក់សំរាប់ការងារដែលបានធ្វើ

⇒ រឿងបណ្តឹងក្តីតូចតាចនិងបណ្តឹងស៊ីវិល

⇒ កន្លែងធ្វើការ- ទំនាក់ទំនង, រឿងក្តីដែលមិនមានពាក់ព័ន្ធនឹងរឿងតវ៉ាបាតុកម្ម